គណបក្ស សិទ្ធិមនុស្ស
HUMAN RIGHTS PARTY
បំរើ ការពារ កសាង

លេខ..០២៧៤/០៩..គ.ស.ម

ភ្នំពេញ, ថ្ងៃទី២២ ខែតុលា ឆ្នាំ ២០០៩

# សេចក្តីថ្លែងការណ៍

## "អបអរសាទរខួបឆ្នាំទី១៨ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ស្តីពីកម្ពុជា"

## ២៣ តុលា ១៩៩១ - ២៣ តុលា ២០០៩

**គណបក្សសិទ្ធិមនុស្ស** (**គ.ស.ម.**) សូមសម្តែងនូវការអបអរសាទររំលឹកថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសស្តីពីកម្ពុជា ។

**គណបក្សសិទ្ធិមនុស្ស**យល់ឃើញថា ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ គឺជាថ្ងៃប្រវត្តិសាស្ត្រដ៏មានសារៈសំខាន់បំផុតសំរាប់ប្រជាពលរដ្ឋខ្មែរគ្រប់និន្នាការនយោបាយទាំងអស់បន្ទាប់ពីថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ដែលជាទិវាឯករាជសំរាប់ជាតិដែលខ្មែរយើងទាំងអស់គ្នាមិនត្រូវបំភ្លេចឡើយ ។

**គណបក្សសិទ្ធិមនុស្ស**សូមរំលឹកថា ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ គឺជាថ្ងៃដែលខ្មែរគ្រប់ភាគីនយោបាយ ប្រទេសជិតខាង និងមហាអំណាចបានព្រមព្រៀងគ្នាជាគោលការណ៍នូវចំណុចសំខាន់ៗដូចខាងក្រោមនេះ :

១. ធានានូវ**ឯករាជភាព** អធិបតេយ្យភាព និងបូរណភាពទឹកដីនៃប្រទេសកម្ពុជា ដោយបញ្ឈប់ការឈ្លានពានរបស់កងទ័ពវៀតណាមមកលើទឹកដីកម្ពុជា ។

២. ធានានូវ**សុខសន្តិភាព**ពិតប្រាកដដល់ប្រទេសកម្ពុជា និងប្រជាពលរដ្ឋខ្មែរគ្រប់រូប ដោយបញ្ឈប់ការប្រមូលផ្តុំអំណាចរដ្ឋ សំរាប់បុគ្គល ឬបក្សពួក ដែលបណ្តាលឱ្យបាត់បង់សន្តិភាពផ្លូវកាយ និងផ្លូវចិត្តប្រជាពលរដ្ឋខ្មែរ ។

៣. ធានានូវ**សិទ្ធិសេរីភាព**ជាមូលដ្ឋានរបស់ប្រជាពលរដ្ឋខ្មែរ ដោយមិនរើសអើង និងមិនរំលោភគំរាមកំហែង ។

៤. ជួយកសាងប្រទេសកម្ពុជា តាមបែបប្រជាធិបតេយ្យ សេរីពហុបក្ស និងជួយអភិវឌ្ឍន៍ប្រទេសកម្ពុជា និងប្រជាពលរដ្ឋខ្មែរឱ្យចាកផុតពីទុក្ខវេទនា និងភាពក្រីក្រ ។

**គណបក្សសិទ្ធិមនុស្ស**យល់ឃើញថា ដោយមានកិច្ចព្រមព្រៀង ២៣ តុលានេះហើយ :

- ដែលបង្ខំឱ្យកងទ័ពឈ្លានពានវៀតណាមដកចេញពីកម្ពុជា
- ដែលកម្ពុជាមានរដ្ឋធម្មនុញ្ញថ្មី ១៩៩៣ មានរបបរាជានិយមអាស្រ័យធម្មនុញ្ញ និងអនុវត្តនូវគោលការណ៍ប្រជាធិបតេយ្យ សេរីពហុបក្ស

Address: #72-74, Street 598, Sangkat Boeung Kok 2, Khan Tuol Kok, Phnom Penh, Cambodia.
Tel: (+855) 17 303 900 / 023 884 649 | Email: hrpcambodia@yahoo.com| Website: www.hrpcambodia.info